**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * *

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានអនុញ្ញាតឱ្យ លោកជំទាវ Eva Nguyen Binh ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពចប់អាណត្តិ នៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា**

* * * * *

នាព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតជូន **លោកជំទាវ Eva Nguyen Binh** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា បន្ទាប់ពីបានបញ្ចប់បេសកកម្មការទូតរបស់លោកជំទាវ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរលោកជំទាវ ដែលត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបារាំង និងជាឯកអគ្គរដ្ឋទូតទទួលបន្ទុកបេសកកម្មសម្រាប់សកម្មភាពវប្បធម៌បារាំងនៅក្រៅប្រទេស និងបានជូនពរលោកជំទាវ សូមទទួលបានជោគជ័យបន្ថែមទៀតក្នុងការបំពេញភារកិច្ចថ្មី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ពីការត្រៀមបន្តផ្តល់ការគាំទ្រ និងកិច្ចសហការជិតស្និទ្ធជូនចំពោះឯកអគ្គរដ្ឋទូតបារាំងថ្មី ដែលនឹងចូលកាន់តំណែងក្នុងពេលឆាប់ៗខាងមុខនេះ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលដ៏ល្អប្រសើររបស់ **លោកជំទាវឯកអគ្គរដ្ឋទូត** ក្នុងការចូលរួមពង្រឹង និងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងបារាំង ក៏ដូចជាការអភិវឌ្ឍនៅកម្ពុជា ក្នុងវិស័យជាច្រើនរួមមាន ពាណិជ្ជកម្ម អប់រំ សុខាភិបាល វប្បធម៌ ការពារជាតិ យុត្តិធម៌ ទឹកស្អាត ថាមពល កសិកម្ម និងអភិវឌ្ឍជនបទ ជាដើម។

**លោកជំទាវឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ផ្ទាល់ ក៏ដូចជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នរដ្ឋគ្រប់ជាន់ថ្នាក់ ដែលបានផ្តល់ការគាំទ្រ និងជួយសម្រួលយ៉ាងពេញទំហឹងដល់បេសកម្មការទូតរបស់លោកជំទាវ នាពេលកន្លងមក។

ទន្ទឹមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងអំពីការត្រៀមខ្លួន ក្នុងការធ្វើជាម្ចាស់ផ្ទះ កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០២១ និង ការធ្វើជាប្រធានអាស៊ាន នាឆ្នាំ២០២២ ខាងមុខនេះ។

ជាកិច្ចឆ្លើយតប **លោកជំទាវឯកអគ្គរដ្ឋទូត** បានជម្រាបជូនថា ថ្នាក់ដឹកនាំបារាំងមានបំណងអញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣នៅកម្ពុជា។ ទន្ទឹមនេះ **លោកជំទាវឯកអគ្គរដ្ឋទូត** ក៏បានជម្រាបជូនផងដែរថា ប្រទេសបារាំងនឹងធ្វើជាប្រធានប្តូរវេននៃក្រុមប្រឹក្សាសហភាពអឺរ៉ុប ចាប់ពីខែមករា ដល់ចុងខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ។

ក្នុងន័យនេះ ក្នុងនាមកម្ពុជាជាប្រធានអាស៊ាន និងក្នុងនាមបារាំងជាប្រធានប្តូរវេននៃក្រុមប្រឹក្សាសហភាពអឺរ៉ុប នៅក្នុងឆមាសទី១ ឆ្នាំ២០២២ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវឯកអគ្គរដ្ឋទូត** បានយល់ស្របគ្នាថានឹងធ្វើកិច្ចការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការល្អរវាងអង្គការតំបន់ទាំងពីរ។

កិច្ចសន្ទនាបានប្រព្រឹត្តទៅក្នុងបរិយាកាសមិត្តភាពកក់ក្តៅក្រៃលែង ដែលឆ្លុះបញ្ចាំងពីចំណងមិត្តភាពជាយូរលង់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង។

-------------------